**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៤៩៣ មស.ស.ធខ

ថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨

**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ ៖** សំណើសុំចាត់តាំងមន្ត្រីរាជការស៊ីវិលចូលរួមប្រឡងត្រួតពិនិត្យសមត្ថភាព ដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្ត សម្រាប់ឆ្នាំ២០១៨ នៅសាលាភូមិន្ទរដ្ឋបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា នៅឆ្នាំ២០១៨នេះ សាលាភូមិន្ទរដ្ឋបាលនឹងរៀបចំបើកវគ្គបណ្តុះបណ្តាលបន្តសម្រាប់មន្ត្រីរាជការស៊ីវិលក្នុងតំណែង និងមន្ត្រីរាជការស៊ីវិលមានក្របខណ្ឌក្នុងមុខងារសាធារណៈ ដែលរួមមានវគ្គបណ្តុះបណ្តាលបន្តមន្ត្រីជាន់ខ្ពស់ និងវគ្គបណ្តុះបណ្តាលបន្តមន្ត្រីមធ្យម។ វគ្គបណ្តុះបណ្តាលបន្តមានរយៈពេល៩ខែ ដែលក្នុងនោះរួមមានការសិក្សាទ្រឹស្តី ការអនុវត្តជាក់ស្តែង និងការអនុវត្តការងារសកម្មភាពសង្គម។ ដោយផ្អែកលើតួខណ្ឌ និងស្ថានភាពជាក់ស្តែងសម្រាប់ឆ្នាំ២០១៨នេះ សាលាភូមិន្ទរដ្ឋបាលបានកំណត់យកការបណ្តុះបណ្តាលបន្ត ដែលរួមមានវគ្គក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងវគ្គក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាលចំនួនសរុប ១៦០នាក់ ព្រមទាំងវគ្គក្រឹត្យការមន្ត្រីមធ្យម និងវគ្គក្រឹត្យការមន្ត្រីក្រមការចំនួនសរុប ១៦០នាក់។ ក្នុងន័យនេះខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ការបញ្ជូនមន្ត្រីរាជការស៊ីវិលចូលរួមជាបេក្ខជនប្រឡងត្រួតពិនិត្យសមត្ថភាពដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៨នាពេលខាងមុខនេះ គឺមិនមានការកំណត់ចំនួននោះទេ។

សូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាចាត់តាំងមន្ត្រីរាជការស៊ីវិលចូលរួមក្នុងការប្រឡងដោយផ្អែកលើលក្ខណវិនិច្ឆ័យ ដូចខាងក្រោម៖

១) វគ្គបណ្តុះបណ្តាលបន្តមន្ត្រីជាន់ខ្ពស់

ក) វគ្គក្រឹត្យការមន្ត្រីជាន់ខ្ពស់

- រដ្ឋបាលថ្នាក់ជាតិ ៖ មន្ត្រីរាជការស៊ីវិលកំពុងកាន់តំណែងចាប់ពី អនុប្រធាននាយកដ្ឋានឡើងទៅ (មិនមែនមន្ត្រីនយោបាយមានឋានៈស្មើ)
- រដ្ឋបាលថ្នាក់ក្រោមជាតិ ៖ មន្ត្រីរាជការស៊ីវិលកំពុងកាន់តំណែងជាអភិបាល អភិបាលរងរាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលារាជធានី ខេត្ត ប្រធានមន្ទីរជុំវិញរាជធានី ខេត្ត ឬតំណែងប្រហាក់ប្រហែលក្នុងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន(មិនមែនមន្ត្រីនយោបាយមានឋានៈស្មើ)
- អតីតភាពការងារយ៉ាងតិច ៣ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

ខ) វគ្គក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល

- រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ៖ មន្ត្រីរាជការស៊ីវិលក្របខណ្ឌ (ក)
- អតីតភាពការងារយ៉ាងតិច ៣ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ



ផ្លូវវិថីអង្គតាមិញ កូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

២) វគ្គបណ្តុះបណ្តាលបន្តមន្ត្រីមធ្យម

ក) វគ្គវិក្រឹត្យការមន្ត្រីមធ្យម

- រដ្ឋបាលថ្នាក់ជាតិ ៖ មន្ត្រីរាជការស៊ីវិលកំពុងកាន់តំណែងចាប់ពីថ្នាក់ប្រធានការិយាល័យចុះ (មិនមែនមន្ត្រីនយោបាយមានឋានៈស្មើ)
- រដ្ឋបាលថ្នាក់ក្រោមជាតិ ៖ មន្ត្រីរាជការស៊ីវិលកំពុងកាន់តំណែងជាអភិបាលរងក្រុង ស្រុក ខណ្ឌ នាយករង រដ្ឋបាលសាលារាជធានី ខេត្ត អនុប្រធានមន្ទីរជុំវិញរាជធានី ខេត្ត នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ឬតំណែងប្រហាក់ប្រហែលក្នុងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន (មិនមែនមន្ត្រីនយោបាយមាន ឋានៈស្មើ)
- អតីតភាពការងារយ៉ាងតិច ២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

ខ) វគ្គវិក្រឹត្យការមន្ត្រីក្រមការ

- រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ៖ មន្ត្រីរាជការស៊ីវិលក្របខណ្ឌ (ខ)
- អតីតភាពការងារយ៉ាងតិច ២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

ទន្ទឹមនេះ ក្រសួង ស្ថាប័នត្រូវបញ្ជូនឈ្មោះមន្ត្រីរាជការស៊ីវិលចូលរួមប្រឡងត្រួតពិនិត្យសមត្ថភាព ដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៨ មកសាលាភូមិន្ទរដ្ឋបាលឲ្យបានមុនថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨។ ក្នុងករណីពុំមានការបញ្ជូនបញ្ជីឈ្មោះមន្ត្រីរាជការស៊ីវិលតាមកាលកំណត់ មានន័យថាក្រសួង ស្ថាប័នពុំមានតម្រូវការក្នុងការបណ្តុះបណ្តាលនោះឡើយ។ មន្ត្រីរាជការស៊ីវិលម្នាក់ៗ ដែលត្រូវបានចាត់តាំងឲ្យមកចូលរួមក្នុងការប្រឡងត្រួតពិនិត្យសមត្ថភាពដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៨ ត្រូវបំពេញបែបបទតាមប្រព័ន្ធ Online លើគេហទំព័រសាលាភូមិន្ទរដ្ឋបាល sms.era.gov.kh ដោយភ្ជាប់មកជាមួយនូវ៖

១) ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស បញ្ជាក់ពីការចូលបម្រើការងារក្នុងមុខងារសាធារណៈ
២) ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬដីកាបញ្ជាក់ពីការតែងតាំងក្នុងតំណែង សម្រាប់វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងវគ្គវិក្រឹត្យការមន្ត្រីមធ្យម
៣) ប្រវត្តិរូបសង្ខេបបញ្ជាក់ដោយនាយកដ្ឋានឬអង្គភាពទទួលបន្ទុកកិច្ចការបុគ្គលិករបស់ក្រសួង ស្ថាប័ន ឬប្រធានអង្គភាពគ្រប់គ្រងមន្ត្រីផ្ទាល់ (អាចទាញយកពីគេហទំព័រសាលាភូមិន្ទរដ្ឋបាល sms.era.gov.kh)
៤) លិខិតបង្ហាញហេតុ (Motivation Letter) របស់សាមីខ្លួន (អាចទាញយកពីគេហទំព័រសាលាភូមិន្ទរដ្ឋបាល sms.era.gov.kh)
៥) សញ្ញាបត្រខ្ពស់ជាងគេ(ឧទាហរណ៍៖ សញ្ញាបត្របណ្ឌិត បរិញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្រ ឬបរិញ្ញាបត្ររង)។

ចំណែកមន្ត្រីរាជការស៊ីវិលមានឈ្មោះក្នុងតារាងបញ្ជីចាត់បញ្ជូនដោយក្រសួង ស្ថាប័នសាមីនឹងត្រូវបំពេញបែបបទតាមប្រព័ន្ធ Online **ចាប់ពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ ជាកំហិត។**

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងសូមមានចំណាត់ការដ៏ខ្ពង់ខ្ពស់តាមការគួរ។

សូម **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- សមាជិកក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល
- ឯកសារ-កាលប្បវត្តិ

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**
- លោក ស្រ៊ាង ផានិត ០៧៧ ២៨៨ ៩៨៨
- លោក អ៊ុច មុនី ០១២ ៧៩៧ ៧៤៩
- លោក ផូ ភិន៍ហ៊ាន ០១២ ៨៦៩ ៩០៤